## នាយកដ្ឋានសហការគ្នាជាក្រុមគ្រួសារ សាលារៀន និងប្រជាសហគមន៍

1000 Broadway, Suite 150
Oakland, CA 94607
(510) 879-2742

នាយកដ្ឋានសហការគ្នាជាមួយក្រុមគ្រសារ សាលារៀន និងប្រជាសហគមន៏នៃសង្កាត់សាលារៀនអូកឡិនដ៍ បំរើសេវាដូចតទៅនេះ សំរាប់កូនសិស្សរបស់យើង៖

- កម្មវិធីបន្ទាប់ពីសាលារៀន
- ផ្នែកបំរើសេវាទ្រទ្រង់វត្តមាន និងផ្នែកដាក់វិន័យ
- ផ្នែកសុខភាពអាកប្បកិរិយា
- ផ្នែកសុខភាព និងសុខមាលភាព
- មណ្ឌល ផ្តល់យុត្តិធម៌/ផ្លាស់ប្តូរ សំរាប់ក្មេងពុំទាន់គ្រប់អាយុ
- ផ្នែករៀនសូត្រអំពីសង្គម និងផ្លូវចិត្ត
- មណ្ឌលចុះឈ្មោះរៀនសំរាប់កូនសិស្ស
- ផ្នែកទាក់ទងកូនសិស្ស និងក្រុមគ្រួសារ
- ផ្នែករៀនសូត្រនារដូវក្តៅ
- ផ្នែកកូនសិស្ស និងក្រុមគ្រួសារអន្តរកាល

### តើអ្នកមានសំណួរនានាអំពីផែនការ 504 ដែរទេ?

សាលារៀននីមួយៗ មានសមាជិកបុគ្គលិកម្នាក់ ដែលបំរើការក្នុងនាមជាអ្នកសម្របសម្រួលផែនការ 504។ បុគ្គលិករូបនេះ ជាអ្នករកដំណោះស្រាយសំរាប់ផែនការ 504 ទាំងអស់ នៅតាមទីសាលារៀន ហើយជាមនុស្សដ៏សំខាន់ម្នាក់ដែរ សំរាប់មាតាបិតា។ សូមទូរស័ព្ទទៅកាន់សាលារៀន រួចស្នើសុំជួបអ្នកសម្របសម្រួលផែនការ 504។

មានអ្នកសម្របសម្រួលផែនការ 504 ម្នាក់ប្រចាំសង្កាត់ផងដែរ ដែលជាអ្នកត្រួតពិនិត្យដំណើរការនៃផែនការ 504 នៅគ្រប់ទីសាលារៀនទាំងអស់នៃសង្កាត់សាលារៀនអូកឡិនដ៍។ (អ្នកស្រី Barbara Parker ជាអ្នកសម្របសម្រួលផែនការ 504 (504@ousd.org; (510) 879-2357; 1000 Broadway, Oakland, CA 94607)។

# គោលការណ៍ណែនាំសំរាប់មាតាបិតា៖
# ផែនការ 504 សំរាប់កូនសិស្សពិការ

ផ្នែក 504 គឺជាផ្នែកនៃច្បាប់សហរដ្ឋ ដែលហាមប្រាមសាលារៀន មិនឱ្យមានការរើសអើងកូនសិស្សពិការទាំងឡាយ។ ច្បាប់នេះចែងផងដែរថា សាលារៀនត្រូវតែបំពេញសេចក្តីត្រូវការនៃកម្មវិធីអប់រំនៃកូនសិស្សពិការឱ្យបានគ្រប់គ្រាន់ ដូចគ្នានឹងសេចក្តីត្រូវការនៃកម្មវិធីអប់រំ ដែលពួកគេបានផ្តល់ឱ្យកូនសិស្សដែលពុំមានភាពពិការអញ្ចឹងដែរ។

នៅពេលណាកូនសិស្សពិការទទួលបាននូវផែនការ 504 ហើយនោះ ពួកគេនឹងបានដឹងថា តើសាលារៀននឹងធ្វើអ្វីខ្លះ ដើម្បីជួយឱ្យផែនការនេះ បំពេញសេចក្តីត្រូវការនៃកម្មវិធីអប់រំ សំរាប់កូនសិស្សម្នាក់ៗ។

ប្រសិនបើលោកអ្នកគិតថា កូនលោកអ្នកត្រូវការផែនការ 504 នោះ កូនសៀវភៅមួយក្បាលនេះ នឹងជួយពន្យល់អំពីលក្ខខណ្ឌនានា ហើយនិងជំរាបជូនអំពីអ្វីៗដែលលោកអ្នកអាចធ្វើបាន។

OAKLAND UNIFIED SCHOOL DISTRICT
*Community Schools, Thriving Students*

# ផែនការ 504

## តើផ្នែក 504 ជាអ្វី៖

ផ្នែក 504 គឺជាច្បាប់សិទ្ធិពលរដ្ឋមួយ ដែលហាមប្រាមសាលារៀន មិនឱ្យមានការរើសអើងជាកូនសិស្សទាំងឡាយដែលមានភាពពិការ។

ដើម្បីការពារកុំឱ្យមានការរើសអើងនេះ សាលារៀននានារបស់យើង ត្រូវតែផ្តល់ឱ្យកូនសិស្សទាំងឡាយដែលមានភាពពិការ នូវឱកាសទទួលបាននូវផលប្រយោជន៍ពីកម្មវិធីបំរើសេវា និងសកម្មភាពនានានៃសាលរៀន ដូចគ្នានឹងកូនសិស្សដែលពុំមានភាពពិការអញ្ចឹងដែរ។

ផ្នែក 504 តម្រូវផងដែរ ឱ្យសាលារៀននានាបំពេញសេចក្តីត្រូវការនានាសំរាប់កូនសិស្សម្នាក់ៗដែលមានភាពពិការ ឱ្យបានគ្រប់គ្រាន់ ដូចគ្នានឹងសេចក្តីត្រូវការនានា ដែលពួកគេបានផ្តល់ឱ្យកូនសិស្សដែលពុំមានភាពពិការអញ្ចឹងដែរ។ ជួនកាល ការនេះមានន័យថា សាលារៀននឹងបង្កើត «ផែនការ 504» សំរាប់កូនសិស្សម្នាក់ដែលមានភាពពិការ។

## តើផែនការ 504 ជាអ្វី?

បើសិនជាកូនសិស្សពិការម្នាក់ បំពេញបានទៅតាមលក្ខខ័ណ្ឌណាមួយហើយនោះ សាលារៀននឹងចាប់ផ្តើមបង្កើតផែនការ 504 សំរាប់ពួកគេ។

ផែនការ 504 រៀបរាប់អំពីអ្វីៗដែលសាលារៀននឹងធ្វើ ដើម្បីធានាយ៉ាងណាឱ្យសេចក្តីត្រូវការនានាសំរាប់កូនសិស្សម្នាក់ៗដែលមានភាពពិការនោះ បំពេញបាននូវផែនការហ្នឹង។ វិធីជួយបែបនេះ ដល់កូនសិស្សដែលមានភាពពិការនោះ យើងហៅថា «ការធ្វើតម្រូវតាមសេចក្តីត្រូវការនានា»។ ផែនការ 504 អាច រួមមានផងដែរ នូវការបំរើសេវាពិសេសៗ ដែលកូនសិស្សត្រូវការ។

ផែនការនានាអាចមានលក្ខណ:ខុសៗគ្នា ពីព្រោះផែនការ 504 នីមួយៗ ត្រូវបានគេរៀបចំឡើងដើម្បីបំពេញសេចក្តីត្រូវការនានាសំរាប់កូនសិស្សម្នាក់ៗ។



## តើកូនសិស្សណាខ្លះ អាចទទួលបាននូវផែនការ 504?

ដើម្បីឱ្យទទួលបាននូវផែនការ 504 នោះ កូនសិស្សម្នាក់ត្រូវតែបំពេញតាមលក្ខខណ្ឌទាំង 3 នេះ៖

1. **កូនសិស្សត្រូវតែមាន *ភាពទន់ខ្សោយខាងផ្លូវកាយ ឬផ្លូវចិត្ត* ដែលធ្វើឱ្យពួកគេមានការពិបាករៀនសូត្រ ឬចូលរួមក្នុងកម្មវិធី ឬក្នុងសកម្មភាពនានានៃសាលារៀន។**

   «ភាពទន់ខ្សោយខាងផ្លូវកាយ ឬផ្លូវចិត្ត» អាចជាបញ្ហាខាងផ្លូវកាយ ឬខាងផ្លូវចិត្ត។ វាអាចជាបញ្ហាមួយដែលកើតមានរយ:ពេលខ្លី ឬរយ:ពេលយូរ ឬអាចនិយាយបានថា ម្តងមាន ម្តងអត់ ក៏អាចថាបាន។

   តួយ៉ាងនៃភាពទន់ខ្សោយ រួមមានដូចជា ភាពមិនចេះនៅសុខ (ADHD); បញ្ហាខាងសតិ ឬវិបត្តិផ្លូវចិត្ត; ជម្ងឺមហារីក; ជម្ងឺហឺតរុំារ៉ៃ; ជម្ងឺទឹកនោមផ្អែម; ជម្ងឺប្រកាច់; ឬអសមត្ថភាពខាងការរៀនសូត្រ។

2. **ភាពទន់ខ្សោយរបស់កូនសិស្ស ត្រូវតែមានលក្ខណ:ប៉ះពាល់ យ៉ាងហោចណាស់ ទៅលើសកម្មភាពមួយ ក្នុង «សកម្មភាពចំបងៗជាប្រចាំ»។** សកម្មភាពចំបងៗជាប្រចាំ រួមមាន ដូចជាការមើលឃើញ, ការស្តាប់ឮ, ការនិយាយ, ការដើរ, ការគិត, ការរៀនសូត្រ និងការធ្វើការងារ។ សកម្មភាពចំបងៗជាប្រចាំ រួមមានផងដែរ ប្រតិបត្តិការនៃមុខងារនៃរាងកាយដ៏ធំមួយ ដូចជាការរីកចំរើនធម្មតានៃមុខងារកោសិកា, ប្រព័ន្ធការពាររបស់សារពាង្គកាយប្រឆាំងទល់នឹងមេរោគ, និងពោះ វៀន, ប្លោកនោម, អន្តោមញ្ញ៉ន, ប្រសាទ និងមុខងារឈាមរត់ជុំវិញដងខ្លួន។

3. **ភាពទន់ខ្សោយ ត្រូវតែមានលក្ខណ:ដែលធ្វើឱ្យមានការពិបាកខ្លាំង ក្នុងការធ្វើកម្មភាពចំបងៗ**

   ការកំណត់ថាតើ ភាពទន់ខ្សោយ មានលក្ខណ:ធ្វើឱ្យមានការពិបាកខ្លាំង ក្នុងការធ្វើសកម្មភាពចំបងៗនោះ គឺត្រូវការវង្វាយតម្លៃសំរាប់មនុស្សម្នាក់ៗ ប៉ុន្តែពុំមែនជាការវិភាគទូលំទូលាយនោះទេ។ ភាពទន់ខ្សោយ ពុំមែនទាល់តែថា មានលក្ខណ:រារាំង ឬធ្វើឱ្យមានការពិបាកខ្លាំង ក្នុងការធ្វើសកម្មភាព ទើបអាចចាត់ទុកបានថាជា «ការធ្វើឱ្យមានការពិបាកខ្លាំង» នោះទេ។

   បើសិនជា ភាពទន់ខ្សោយខាងភ្នែក អាចធ្វើការកែតម្រូវទាំងស្រុងវិញបាន តាមការប្រើវ៉ែនតាធម្មតា ឬឡងទីបិតជាប់ភ្នែក (contact lenses) នោះ វានឹងពុំត្រូវបានចាត់ទុកថាជា ការធ្វើឱ្យមានការពិបាកខ្លាំង ក្នុងមើលឃើញនោះទេ។

## តើធ្វើដូចម្តេចទើបកូនសិស្សអាចទទួលបាននូវផែនការ 504 នេះ?

មានសមាជិកបុគ្គលិកនៅតាមទីសាលារៀននីមួយៗ ដែលបំរើការក្នុងនាមជាអ្នកសម្របសម្រួលផែនការ 504 ហើយជាអ្នកកាន់កាប់ផែនការ 504 នៅឯសាលារៀនហ្នឹង។ ប្រសិនបើមាននរណាម្នាក់ឃើញថា មានកូនសិស្សម្នាក់ដែលមានភាពទន់ខ្សោយក្នុងលក្ខណៈណាមួយ ដែលស្របតាមតម្រូវការនានា សំរាប់ផែនការ 504 នោះ អ្នកសម្របសម្រួលផែនការ 504 រូបនោះ នឹងចាត់វិធានការជួយទៅតាមហ្នឹង។

តាមធម្មតា មាតាបិតា គ្រូបង្រៀន អ្នកគ្រូពេទ្យប្រចាំសាលារៀន ឬបុគ្គលិកសាលារៀន ជាអ្នកប្រាប់ដល់អ្នកសម្របសម្រួលផែនការ 504 អំពីកូនសិស្សណាម្នាក់ដែលអាចត្រូវការផែនការ 504។

# បើសិនជាលោកអ្នក គិតថាកូនលោកអ្នក ត្រូវការផែនការ 504 តើលោកអ្នកត្រូវធ្វើអ្វីខ្លះ?

## ទំនាក់ទំនងជាមួយសាលារៀនរបស់កូនលោកអ្នក

ដើម្បីចាប់ផ្តើមការនេះ សូមជួបនិយាយជាមួយនឹងអ្នកសម្របសម្រួលផែនការ 504 នៅឯសាលារៀនរបស់កូនលោកអ្នកចុះ។ (ទូរស័ព្ទទៅកាន់ការិយាល័យនៃសាលារៀនរបស់កូនលោកអ្នក រួចស្នើសុំជួបជាមួយអ្នកសម្របសម្រួលផែនការ 504។)

អ្នកសម្របសម្រួលផែនការ 504 នឹងជួយលោកអ្នក ក្នុងការធ្វើក្រដាស់ស្នាម សំរាប់ដាក់ស្នើសុំ «រង្វាយតម្លៃ 504» ដើម្បីឱ្យដឹងថា តើកូនលោកអ្នកបំពេញតម្រូវការនានា ដើម្បីឱ្យអាចទទួលបាននូវផែនការ 504 ឬយ៉ាងណា។ អ្នកសម្របសម្រួលផែនការ 504 នឹងពិនិត្យមើលសំណើរបស់លោកអ្នកសំរាប់រង្វាយតម្លៃនៃផែនការ 504 រួចមកគេនឹងឆ្លើយតបជូនលោកអ្នកវិញឱ្យបានជ្រាបក្នុងរយៈពេល 15 ថ្ងៃ។

- បើសិនជាសង្កាត់គិតថាកូនលោកអ្នកត្រូវការរង្វាយតម្លៃនៃផែនការ 504 នោះ អ្នកសម្របសម្រួលផែនការ 504 នៅឯសាលារៀនរបស់កូនលោកអ្នក នឹងផ្តល់ជូនលោកអ្នកនូវក្រដាស់ស្នាម ដែលប្រាប់អំពីរបៀបដែលសាលារៀនធ្វើការវាយតម្លៃលើកូនលោកអ្នក។ លោកអ្នកត្រូវតែចុះហត្ថលេខា រួចបញ្ជូនក្រដាស់ស្នាមនេះ ទៅឱ្យសាលារៀនវិញ ហើយបន្ទាប់មក គេនឹងចាប់ផ្តើមធ្វើការវាយតម្លៃលើកូនលោកអ្នកតែម្តង។

- សង្កាត់អាចសំរេចចិត្តថា កូនលោកអ្នកមិនត្រូវការរង្វាយតម្លៃ 504 នេះទេ។ ប្រសិនបើលោកអ្នកមិនយល់ស្របទៅតាមការសំរេចចិត្តនេះទេនោះ លោកអ្នកមានសិទ្ធិស្នើសុំឱ្យគេធ្វើការសំរេចចិត្តសារជាថ្មីបាន (ផ្នែកបន្ទាប់មកទៀត នឹងរៀបរាប់ជូនថែមទៀត នូវព័ត៌មានស្តីពីសិទ្ធិរបស់លោកអ្នក)។



## ប្រសិនបើកូនលោកអ្នក ទទួលបាននូវការវាយតម្លៃសំរាប់ផែនការ 504 ហើយនោះ តើនឹងមានអ្វីកើតឡើងបន្ទាប់មកទៀត?

នៅក្នុងពេលវាយតម្លៃដោយផែនការ 504 នេះ អ្នកសម្របសម្រួលផែនការ 504 នឹងប្រមូលព័ត៌មានពីលោកអ្នក រួមទាំងឯកសារជាលាយលក្ខអក្សរណាមួយអំពីកូនលោកអ្នក ដែលលោកអ្នកប្រាថ្នាចង់បានដាក់ចែករំលែក, សំណុំរឿងសិក្សារបស់កូនលោកអ្នក និងបុគ្គលិកសាលារៀនណាដែលដឹងអំពីសេចក្តីត្រូវការរបស់កូនលោកអ្នក។ បុគ្គលិកសាលារៀនអាចរៀបចំផងដែរ សំរាប់ការធ្វើតេស្តដើម្បីឱ្យបានយល់ច្បាស់ អំពីសេចក្តីត្រូវការនានាសំរាប់ការអប់រំរបស់កូនលោកអ្នក។

ជំហានបន្ទាប់មកទៀត គឺធ្វើកិច្ចប្រជុំនៃក្រុម 504 ដើម្បីពិនិត្យមើលព័ត៌មានទាំងអស់ អំពីសេចក្តីត្រូវការរបស់កូនលោកអ្នក រួចធ្វើការសំរេចចិត្ត ថាតើកូនលោកអ្នកបំពេញបានតាមលក្ខខណ្ឌនានា ដើម្បីឱ្យអាចទទួលបាននូវផែនការ 504 ឬយ៉ាងណា។ កិច្ចប្រជុំនេះ រួមមានទាំងរូបលោកអ្នក អ្នកសម្របសម្រួលនៃផែនការ 504 គ្រូបង្រៀនរបស់កូនលោកអ្នក ហើយនិងបុគ្គលិកសាលារៀនផ្សេងៗទៀត ដែលជួយឱ្យកូនលោកអ្នក ដូចជាអ្នកផ្តល់ឱវាទប្រចាំសាលារៀន ឬអ្នកគ្រូពេទ្យប្រចាំសាលារៀន។

- ប្រសិនបើលោកអ្នកបំពេញបានទៅតាមលក្ខខណ្ឌនានាហើយនោះ ក្រុមគេនឹងរៀបចំផែនការ 504 សំរាប់កូនលោកអ្នកនៅក្នុងកិច្ចប្រជុំ។ ផែនការនេះ រៀបរាប់ជូនអំពីអ្វីៗ ដែលសាលារៀននឹងធ្វើ ដើម្បីជួយធ្វើយ៉ាងណាឱ្យសេចក្តីត្រូវការនៃកម្មវិធីអប់រំបុគ្គលសំរាប់កូនលោកអ្នកនោះ ត្រូវបានគេធ្វើតម្រូវសេចក្តីត្រូវការនៅឯសាលារៀន។ អ្នកសម្របសម្រួលផែនការ 504 នឹងផ្តល់ជូនលោកអ្នក និងមនុស្សផ្សេងៗទៀត នូវផែនការនេះមួយច្បាប់។

- បើសិនជាក្រុម 504 ធ្វើការសំរេចចិត្តថា កូនលោកអ្នកបំពេញពុំបានទៅតាមលក្ខខណ្ឌនានា ដើម្បីឱ្យអាចទទួលបាននូវផែនការ 504 ទេនោះ លោកអ្នកមានសិទ្ធិស្នើសុំឱ្យគេធ្វើកិច្ចសំរេចចិត្តសារជាថ្មីឡើងវិញបាន (ផ្នែកបន្ទាប់មកទៀតស្តីអំពីសិទ្ធិរបស់លោកអ្នក រៀបរាប់ជូនថែមទៀតអំពីសិទ្ធិនេះ)។

## អ្នកសម្របសម្រួលផែនការ 504 ធ្វើការត្រួតពិនិត្យលើផែនការ 504

បើសិនជាកូនលោកអ្នក ទទួលបាននូវផែនការ 504 ហើយនោះ អ្នកសម្របសម្រួលផែនការ 504 នៃសាលារៀន នឹងធ្វើការពិនិត្យមើលតាមពេលកំណត់ ដើម្បីធ្វើយ៉ាងណាឱ្យផែនការនេះ ត្រូវបានគេប្រតិបត្តិតាមត្រឹមត្រូវ ហើយថាក្រុម 504 របស់កូនលោកអ្នកនោះ នឹងធ្វើការពិនិត្យមើលលើផែនការនេះ នៅក្នុងឆ្នាំនីមួយៗ។ ក្រៅពីនេះ អ្នកសម្របសម្រួលផែនការ 504 នឹងពិនិត្យមើលជាមួយលោកអ្នក និងជាមួយនឹងមនុស្សផ្សេងៗទៀត តាមពេលកំណត់ ដើម្បីឱ្យដឹងថា តើផែនការ 504 នេះ មានប្រសិទ្ធិភាពដល់កំរិតណា ហើយថាតើវាត្រូវការការផ្លាស់ប្តូរអ្វីថែមទៀតដែរឬយ៉ាងណា។

# តើលោកអ្នកមានសិទ្ធិអ្វីខ្លះ?

## សាលារៀនត្រូវតែពិចារណាតាមសំណើរបស់លោកអ្នក

ក្នុងនាមជាមាតាបិតា ឬអ្នកអាណាព្យាបាល លោកអ្នកមានសិទ្ធិស្នើសុំឱ្យបុគ្គលិកសាលារៀន ធ្វើការពិចារណាថា តើកូនលោកអ្នកអាចត្រូវការផែនការ 504 ឬយ៉ាងណា ដោយផ្អែកលើព័ត៌មានដែលទទួលបានពីប្រភពខុសៗគ្នា។

## សាលារៀនត្រូវតែមានព័ត៌មានជាស្រេចសំរាប់ពេលលោកអ្នកត្រូវការ

- លោកអ្នកមានសិទ្ធិទទួបាននូវព័ត៌មានទាំងអស់ ជាភាសាកំណើតរបស់លោកអ្នក តាមវិធីចំបង ដែលលោកអ្នកធ្វើការប្រាស្រ័យទាក់ទងគ្នា។
- លោកអ្នកមានសិទ្ធិពិនិត្យមើលសំណុំរឿងទាំងអស់ អំពីផែនការ 504 របស់កូនលោកអ្នក ឬមានសិទ្ធិស្នើសុំផែនការ 504។
- លោកអ្នកមានសិទ្ធិទទួលបាននូវសេចក្តីជូនដំណឹង មុនពេលមានចំណាត់ការណាមួយ ដែលសាលារៀនគ្រោងនឹងធ្វើ ដែលជាប់ពាក់ពាន់ទៅនឹងផែនការ 504 របស់កូនលោកអ្នក ឬធ្វើការស្នើសុំផែនការ 504។
- លោកអ្នកមានសិទ្ធិស្នើសុំឱ្យគេធ្វើការពិនិត្យ និងធ្វើការវាយតម្លៃលើផែនការ 504 របស់កូនលោកអ្នក តាមពេលកំណត់ទៀងទាត់។ លោកអ្នកមានសិទ្ធិស្នើសុំឱ្យគេផ្តល់ដំណឹងប្រាប់ជាមុនសិន មុននឹងមានការផ្លាស់ប្តូរសំខាន់ៗណាមួយ លើការបំរើសេវាដែលកូន លោកអ្នកបានទទួលតាមផែនការ 504។

## នីតិវិធីដាក់វិន័យសំរាប់កូនសិស្សដែលមានផែនការ 504

បើសិនជាកូនសិស្សនៃផែនការ 504 ប្រព្រឹត្តក្នុងលក្ខណៈដែលអាចបណ្តាលឱ្យមានការបណ្តេញចេញពីសាលារៀន ឬត្រូវបានបញ្ឈប់បណ្តោះអាសន្នពីសាលារៀន អស់រយៈពេល 10 ថ្ងៃ ឬច្រើនជាងនេះ នៅក្នុងឆ្នាំសិក្សាណាមួយនោះ កិច្ចប្រជុំគ្នាមួយត្រូវតែធ្វើ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីធ្វើការសំរេចចិត្តថា តើអាកប្បកិរិយារបស់កូនសិស្ស កើតចេញដោយផ្ទាល់ពីភាពពិការ ដែលបានពោលនៅក្នុងផែនការ 504 របស់កូនសិស្សដែរឬយ៉ាងណា ហើយបើសិនជាអញ្ចឹងមែននោះ តើការដាក់វិន័យបែបណាទៅ ទើបមានលក្ខណៈសមស្រប។  សំរាប់ព័ត៌មានថែមទៀតអំពីនីតិវិធីនេះ សូមសាកសួរអ្នកសម្របសម្រួល 504។



## ចុះប្រសិនបើលោកអ្នកមិនយល់ស្របតាមការសំរេចចិត្ត?

ប្រសិនបើលោកអ្នកមិនយល់ស្របតាមការសំរេចចិត្ត ឬតាមអ្វីៗដែលសាលារៀនបានគ្រោងនឹងធ្វើនោះ លោកអ្នកមានសិទ្ធិស្នើសុំឱ្យបើកសវនាការដោយឥតមានភាពលំអៀង។ លោកអ្នកមានសិទ្ធិនាំមេធាវីម្នាក់មកក្នុងសវនាការ បើសិនជាលោកអ្នកត្រូវការចាំបាច់។ នៅក្នុងសវនាការ ប្រសិនបើលោកអ្នកមិនយល់ស្របតាមការសំរេចចិត្តដែលបានធ្វើឡើងដោយមន្ត្រីបើកសវនាការនោះ លោកអ្នកមានសិទ្ធិស្នើសុំឱ្យមានការសំរេចចិត្តសារជាថ្មីឡើងវិញបាន។ (សូមមើលខាងក្រោម)។

## ស្នើសុំឱ្យធ្វើការសំរេចចិត្តសារជាថ្មី

ការស្នើសុំឱ្យធ្វើការសំរេចចិត្តសារជាថ្មី មានន័យថា ការធ្វើតាមនីតិវិធីណាមួយ ដែលស្នើសុំឱ្យគេធ្វើការផ្លាស់ប្តូរការសំរេចចិត្តមួយ ដែលលោកអ្នកមិនយល់ស្របជាមួយ។ លោកអ្នកអាចធ្វើការស្នើសុំឱ្យសំរេចចិត្តសារជាថ្មីវិញបាន ប្រសិនបើលោកអ្នកគិតថាកូនលោកអ្នកត្រូវការផែនការ 504 ហើយសង្កាត់ពុំបានផ្តល់ឱ្យ ឬប្រសិនបើលោកអ្នក និងសង្កាត់មិនយល់ស្របតាមអ្វីៗ ដែលគេត្រូវធ្វើតម្រូវសេចក្តីត្រូវការដាក់ក្នុងផែនការ 504 សំរាប់កូនពិការរបស់លោកអ្នក។ លោកអ្នកអាចធ្វើការស្នើសុំឱ្យគេធ្វើការសំរេចចិត្តសារជាថ្មីវិញបានផងដែរ ប្រសិនបើលោកអ្នកទទួលបាននូវផែនការ 504 ហើយលោកអ្នកមិនយល់ស្របតាមសង្កាត់ អំពីកូនលោកអ្នក ដែលត្រូវបានគេបណ្តេញចេញ ឬបញ្ឈប់បណ្តោះអាសន្នពីសាលារៀន។

ដើម្បីស្នើសុំឱ្យគេធ្វើការសំរេចចិត្តសារជាថ្មីនោះ សូមទាក់ទងផ្នែកសុខភាព, ផ្នែកបំរើសេវាសាលារៀនសហគមន៍ និងកូនសិស្ស ឬសង្កាត់សាលារៀនអូកឡិនដ៍ តាមរយៈទូរស័ព្ទលេខ (510) 879-2742; Suite 150, 1000 Broadway, Oakland, CA 94607)។

## ធ្វើការប្តឹងតវ៉ា

ប្រសិនបើលោកអ្នកគិតថា សង្កាត់សាលារៀនអូកឡិនដ៍ ប្រតិបត្តិពុំបានត្រឹមត្រូវតាមដំណើរការនៃផែនការ 504 នោះ លោកអ្នកអាចធ្វើការប្តឹងតវ៉ាបាន។ លោកអ្នកអាចប្តឹងតវ៉ាបានផងដែរ ប្រសិនបើលោអ្នកមានផែនការ 504 ហើយលោកអ្នកគិតថាគេរើសអើងកូនលោកអ្នក។ ដើម្បីធ្វើការប្តឹងតវ៉ា សូមទំនាក់ទំនងជាមួយនឹងអ្នកស្រី Barbara Parker ជាអ្នកសម្របសម្រួលផែនការ 504 ប្រចាំសង្កាត់សាលារៀនអូកឡិនដ៍ (504@ousd.org; (510) 879-2357; 1000 Broadway, Oakland, CA 94610)។ ឬលោកអ្នកអាចដាក់ពាក្យបណ្តឹង តាមការទាក់ទងការិយាល័យសំរាប់សិទ្ធិពលរដ្ឋ តាមរយៈទូរស័ព្ទលេខ (415) 486-5555 ឬអ៊ីមែលទៅ ocr.sanfrancisco@ed.gov ឬតាមការចុចមើលក្នុងគេហទំព័រ http://www2.ed.gov/about/offices/list/ocr/complaint intro.html។